# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៥៧៦/០៦ គ.ជ.ប

## ជំរាបជូន
## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

__កម្មវត្ថុ__ : សំណើសុំអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងតំណាងអង្គការអន្តរជាតិដើម្បីចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៧ ។

__យោង__ : - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៧ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមឧបនាយករដ្ឋមន្ត្រីជ្រាបថា ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០៧ ប្រព្រឹត្តទៅចាប់តាំងពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៦ រហូតដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ ។ ស្របពេលជាមួយនេះដែរ ការចាប់ផ្តើមចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយចាប់ដំណើរការពីដើមខែមករារហូតដល់ពាក់កណ្តាលខែកុម្ភៈ ការបើកយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយចាប់ផ្តើមពី ថ្ងៃទី ១៦-៣០ ខែ មីនា ឆ្នាំ ២០០៧ និងថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ ជាថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត ។

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៧ បានប្រព្រឹត្តទៅដោយមានការចូលរួមសង្កេតមើលដំណើរការបោះឆ្នោតពីគ្រប់មជ្ឈដ្ឋាននានា សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងតំណាងអង្គការអន្តរជាតិ ដើម្បីចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាប់ទទួលពាក្យអ្នកសង្កេតការណ៍អន្តរជាតិពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៦ រហូតដល់ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

អ៊ឹម - សុស្ដី

__សូមជូនភ្ជាប់មកជាមួយ__ :

-ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៧